**លោកស្រី ហ្វ្លាវៀ ផាន់សៀរី**

**ឧត្តមស្នងការរងសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ**
**ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា**

**សិក្ខាសាលាថ្នាក់ជាតិស្តីពីប័ណ្ណកម្មសិទ្ធិដីសហគមន៍ជនជាតិដើមភាគតិច**

**ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ២០១៤ នៅសណ្ឋាគារ អ៊ីម ភីរល ផ្លូវស៊ីសុវត្ថិ ភ្នំពេញ**

**ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ ជាទីគារព**

អរុណសួស្តី។ ថ្ងៃនេះ ខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយដែលបានចូលរួមជាមួយអ្នកទាំងអស់គ្នា។ ខ្ញុំសូមសម្តែងនូវអំណរគុណ និងវាយតម្លៃខ្ពស់ ចំពោះវាគ្មិនដែលមកពីក្រសួងអភិវឌ្ឍជនបទ និងវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល (NGO Forum) ដែលបានរៀបចំព្រឹត្តិការណ៍នេះឡើង រួមទាំងអ្នករៀបចំព្រឹត្តិការណ៍នេះដែលបានអញ្ជើញខ្ញុំចូលរួម។

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស រួមជាមួយដៃគូក្នុងរដ្ឋាភិបាល និងសង្គមស៊ីវិល យល់ថា វាជាព្រឹត្តិការណ៍សំខាន់ចាំបាច់សម្រាប់ដោះស្រាយបញ្ហាប្រឈម និងសម្រួលដល់ការពន្លឿននូវដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីដល់ជនជាតិដើមភាគតិចនៅកម្ពុជា។

នៅក្រោមគោលការណ៍មូលដ្ឋាននៃសកលភាព សមភាព និងភាពគ្មានការរើសអើង ជនជាតិដើមភាគតិចមានសិទ្ធិទទួលបានយ៉ាងពេញលេញតាមច្បាប់អន្តរជាតិ។ "ទោះជាយ៉ាងណាក៏ដោយ ដោយពិចារណាពីចរិតលក្ខណៈសមូហភាពដែលជាប់ពីកំណើតក្នុងវប្បធម៌ សិទ្ធិបុគ្គលតែងតែមិនគ្រប់គ្រាន់ក្នុងការសំដែងពេញលេញដល់សិទ្ធិជនជាតិដើមភាគតិចឡើយ។ ក្រៅពីសិទ្ធិបុគ្គល សិទ្ធិទាំងនេះមានចែងនៅក្នុងសេចក្តីប្រកាសអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច មានបំណងការពារសិទ្ធិសមូហភាពនៃជនជាតិដើមភាគតិច ពីព្រោះការទទួលស្គាល់នូវសិទ្ធិនេះ មានភាពចាំបាច់ ដើម្បីធានាជីវភាពរស់នៅ ការអភិវឌ្ឍន៍ និងសុខុមាលភាពជាបន្តរបស់ជនជាតិដើមភាគតិចដូចមនុស្សដទៃ"។ ដូច្នេះ ជាមួយការផ្តោតយ៉ាងខ្លាំងទៅលើសមភាព ភាពគ្មានការរើសអើង សិទ្ធិសមូហភាព និងសិទ្ធិអភិវឌ្ឍន៍ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស មានមោទនភាពក្នុងការធ្វើការជាមួយរាជរដ្ឋាភិបាលកម្ពុជា រួមទាំងដៃគូអភិវឌ្ឍន៍នានា អង្គការសង្គមស៊ីវិល និងសហគមន៍ជនជាតិដើមភាគតិច ក្នុងការលើកកម្ពស់ និងការការពារសិទ្ធិដីធ្លីរបស់ជនជាតិដើមភាគតិច។

ខ្ញុំយល់ឃើញថា ជនជាតិដើមភាគតិចមានវត្តមាននៅក្នុងចំនួន ១៥ ខេត្ត នៅប្រទេសកម្ពុជា ហើយមានភាសាកំណើតខុសគ្នាចំនួន ២៣ ត្រូវបានកំណត់អត្តសញ្ញាណនៅប្រទេសកម្ពុជា។ ភាពចម្រុះផ្សេងៗពីគ្នាសាកសមនឹងប្រារព្ធអបអរសាទរឡើង ប៉ុន្តែចាំបាច់ត្រូវបានការពារ និងថែរក្សាផងដែរ។

រាជរដ្ឋាភិបាលបានបោះឆ្នោតគាំទ្រនូវសេចក្តីប្រកាសអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច នៅក្នុងមហាសន្និបាតអង្គការសហប្រជាជាតិ។ សេចក្តីប្រកាសនេះបង្កើតក្របខ័ណ្ឌជាសកលនៃ

បទដ្ឋានអប្បបរមានៃការរស់រានមានជីវិត សេចក្តីថ្លៃថ្នូរ សុខុមាលភាព និងសិទ្ធិជនជាតិដើមភាគតិចនៅលើពិភពលោក។ សេចក្តីប្រកាសនេះដោះស្រាយទាំងសិទ្ធិបុគ្គល និងសិទ្ធិសមូហភាព ព្រមទាំងដាក់ឲ្យនៅក្រៅច្បាប់ចំពោះការរើសអើងប្រឆាំងនឹងជនជាតិដើមភាគតិច និងលើកកម្ពស់ការចូលរួមពេញលេញ និងប្រកបប្រសិទ្ធភាព រាល់គ្រប់បញ្ហាដែលគាត់បារម្ភ។ ខ្ញុំកត់សំគាល់ផងដែរថា កម្ពុជាគឺជាប្រទេសទីមួយនៅក្នុងអាស៊ីអាគ្នេយ៍ដីគោក ដែលទទួលស្គាល់សិទ្ធិដីធ្លីពិសេសសម្រាប់មនុស្សមួយក្រុមជាក់លាក់ ដែលត្រូវបានកំណត់អត្តសញ្ញាណជាជនជាតិភាគតិច។

ច្បាប់ភូមិបាល ឆ្នាំ ២០០១ មានសារៈសំខាន់ខ្លាំងណាស់ ពីព្រោះវាទទួលស្គាល់យ៉ាងស្របច្បាប់ជាលើកដំបូងនូវ "ជនជាតិដើមភាគតិច" ថាជាមនុស្សប្រភេទថ្មី និងបង្កើតនូវទស្សនៈសិទ្ធិដីសហគមន៍នៅក្នុងកម្ពុជា។ ច្បាប់ស្តីពីព្រៃឈើ ឆ្នាំ ២០០២ ដើរតាមនិន្នាការដោយទទួលស្គាល់ផងដែរដល់ជនជាតិដើមភាគតិច។ ច្បាប់ទាំងនេះមានសារៈសំខាន់ទាំងអត្ថន័យជានិមិត្តរូប និងជាក់ស្តែង ក្នុងបញ្ហានៃការកំណត់អត្តសញ្ញាណជាសមូហភាព និងបញ្ហាដែលទាក់ទងនឹងសិទ្ធិដីធ្លី និងព្រៃឈើ រួមបញ្ចូលសិទ្ធិដីធ្លីសហគមន៍ និងផលប៉ះពាល់លើជីវភាព សូម្បីតែការរស់រានមានជីវិត គឺស្ថិតក្នុងចំណោមបញ្ហាបន្ទាន់ដែលប្រឈមមុខដោយជនជាតិដើមភាគតិចក្នុងប្រទេសកម្ពុជា ដូចដែលអ្នកបានដឹងលឺមកហើយ។

ចាប់ពីច្បាប់ទាំងនេះបានអនុម័ត ប័ណ្ណកម្មសិទ្ធិដីសហគមន៍ចំនួន ៨ ត្រូវបានផ្តល់អោយប្រជាពលរដ្ឋ ហើយរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជាបានសន្យាជាសាធារណៈថាផ្តល់នូវប័ណ្ណកម្មសិទ្ធិដីសហគមន៍ ចំនួន ១០ ក្នុងមួយឆ្នាំចាប់ពីឆ្នាំនេះ។ ទោះបីវាជាការល្អប្រសើរមួយសម្រាប់ស្ថានភាពបច្ចុប្បន្ន អត្រានេះនឹងនៅតែមានន័យថា ត្រូវការឆ្លងកាត់រយៈពេលច្រើនទស្សវត្សទៀត មុននឹងការផ្តល់ប័ណ្ណកម្មសិទ្ធិដល់ជនជាតិដើមភាគតិចត្រូវបានដោះស្រាយ។ ខ្ញុំស្នើអោយមានមហិច្ឆតាធំជាងនេះទៅទៀត។

ជាមួយការទទួលស្គាល់ស្របច្បាប់នៃអត្ថិភាពជាសមូហភាព និងសិទ្ធិដីធ្លីរបស់ជនជាតិដើមភាគតិច រាជរដ្ឋាភិបាលបានបង្កើតនូវអង្គភាព និងបទបញ្ញាផ្សេងៗ ដែលមានបំណងអនុវត្តសិទ្ធិទាំងនេះប្រកបដោយប្រសិទ្ធភាព។

ហើយការទទួលបានសិទ្ធិទាំងនេះក្នុងការរស់នៅនៃជនជាតិដើមភាគតិចភាគច្រើនបំផុតនៅទូទាំងប្រទេសនេះ គឺនៅតែមានទំហំធំមិនទាន់សម្រេចបាន ប្រសិនបើគ្មានការបែងចែកនៃការវិនិយោគរចនាសម្ព័ន្ធ និងសេដ្ឋកិច្ចគ្រប់គ្រាន់ក្នុងដំណើរការនេះ។ ដំណើរការសម្រាប់សុំប័ណ្ណកម្មសិទ្ធិដីសហគមន៍គឺមានលក្ខណៈស្មុគស្មាញ អស់កម្រៃថ្លៃ យឺតយាវ ដូច្នេះសហគមន៍ជាច្រើនមិនបានទទួលឡើយ ។

ច្បាប់ដដែរនេះ ដែលផ្តល់នូវមូលដ្ឋានគតិយុត្តលើអត្តសញ្ញាណជនជាតិដើមភាគតិចនៅកម្ពុជា ទទួលស្គាល់ផងដែរនូវសិទ្ធិរបស់រដ្ឋក្នុងការផ្តល់ដីសម្បទាន។ គោលបំណងមួយក្នុងចំណោមគោលបំណងជាច្រើនដែលបានបញ្ជាក់ជារឿយៗ នៃចលនាសិទ្ធិជនជាតិដើមភាគតិចនៅកម្ពុជា គឺដើម្បីពង្រឹកការអនុវត្តច្បាប់ភូមិបាលរបស់រដ្ឋ។ ក្នុងការអនុវត្តជាក់ស្តែង វាកើតឡើងក្នុងកម្រិតមួយចំនួន ប៉ុន្តែអាទិភាពត្រូវបានផ្តល់អោយសម្បទានដី។

ប្រមាណជាង ២២% នៃផ្ទៃប្រទេស ត្រូវបានផ្ទេរអោយទៅសាជីវកម្មតាមរយៈប្រភេទផ្សេងៗនៃសម្បទានដី ភាគច្រើនគឺនៅក្នុងខ្ពង់រាបដែលជាដីរបស់ជនជាតិដើមភាគតិចស្ថិតនៅ។ ជាញឹកញាប់បំផុត

វាតែងតែកើតមានដោយគ្មានការព្រមព្រៀងជាសេរី ជាមុន និងការជូនដំណឹង ចំពោះសហគមន៍ជនជាតិដើមភាគតិចដែលពួកគាត់ត្រូវបានដកចេញពីដំណើរការប្រឹក្សាយោបល់ជាមួយអាជ្ញាធរ និង តួអង្គឯកជន។ សហគមន៍ជនជាតិដើមភាគតិចដែលគ្មានកម្មសិទ្ធិដីជាផ្លូវការ ជាទូទៅ ត្រូវបានចាត់ទុកថាមកតាំងទីលំនៅខុសច្បាប់លើដីរដ្ឋ ដូច្នេះពួកគេគ្មានសិទ្ធិកាន់កាប់ទេ។ ជាញឹកញាប់បំផុត ការតវ៉ាត្រូវបានបង្ក្រាបដោយហិង្សា។ ខ្ញុំមកដល់ភ្នំពេញ ខណៈពេលមនុស្សម្នាជាច្រើនកំពុងធ្វើខួបរំលឹកដល់ការស្លាប់របស់សកម្មជនការពារបរិស្ថាន និងសិទ្ធិមនុស្សដ៏លេចធ្លោរ គឺលោកឈុត វុទ្ធី។ ខ្ញុំកាន់តែគិតថា សិទ្ធិបរិស្ថាន និងសិទ្ធិជនជាតិដើមភាគតិច មិនអាចត្រូវបានផ្តាច់ចេញពីបញ្ហាអភិបាលកិច្ចមូលដ្ឋាន យុត្តិធម៌ និងសេរីភាពបញ្ចេញមតិជាមូលដ្ឋាន និងការជួបជុំ។

ការបដិសេធសិទ្ធិដីធ្លី គឺជាបញ្ហាដ៏ធំសម្បើមណាស់សម្រាប់ជនជាតិដើមភាគតិច ពីព្រោះមិនត្រឹមតែអសន្តិសុខដីធ្លីដែលធ្វើអោយបុគ្គល និងគ្រួសាររបស់គេស្ថិតក្នុងហានិភ័យនៃការផ្លាស់ទី និងភាពក្រីក្រ ប៉ុន្តែថែមទាំងអត្តិភាពនៃអត្តសញ្ញាណ និងការប្រតិបត្តិផ្នែកសង្គមវប្បធម៌សមូហភាពរបស់ពួកគេ ដែលត្រូវបានគំរាមកំហែង ដែលផ្សារភ្ជាប់ទៅនឹងរូបភាពប្រកបដោយនិរន្តរភាពនៃការកាន់កាប់ដីធ្លីនៅទីកន្លែងជាក់លាក់ក្នុងរយៈពេលយូរអង្វែង។ ការបាត់បង់នូវព្រៃជំនឿ និងព្រៃកប់ខ្មោច គឺបំផ្លាញនូវរបៀបរស់នៅដោយឡែករបស់ពួកគេ។

ការព្រមព្រៀងគឺថាមានការផ្តល់គ្រប់គ្រាន់នៅក្របខ័ណ្ឌគតិយុត្ត ដើម្បីអនុញ្ញាតការការពារសិទ្ធិដីធ្លីរបស់ជនជាតិដើមភាគតិចនៅកម្ពុជា។ អ្វីជាគន្លឹះនៅពេលនេះ គឺដើម្បីដោះស្រាយការអនុវត្ត និងការអនុលោមតាមច្បាប់។ ទោះបីជាច្បាប់ជាតិមានសារៈសំខាន់ជាសារវ័ន្តសម្រាប់ជនជាតិដើមភាគតិចក្នុងការបន្តសិទ្ធិដីសហគមន៍ក៏ដោយ អ្នកវិភាគឯករាជ្យមួយចំនួនសំណូមពរថា ច្បាប់នេះមិនត្រូវប្រើដើម្បីការពារភាពរើសអើងអោយបន្តមានដែលប្រឆាំងក្រុមជនជាតិដើមភាគតិចឡើយ និងជម្រើសនៃរបបសម្បទានដីដែលជាយុទ្ធសាស្រ្តអំណោយផលដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច គឺបន្តដកសិទ្ធិរបស់ពួកគាត់។

ខណៈដែលប័ណ្ណកម្មសិទ្ធិ ទំនងជាបន្ទុកការងារសម្រាប់ជាតិក្នុងរយៈពេលជាច្រើនឆ្នាំទៅមុខទៀត បញ្ហាពិតប្រាកដដែលដែលយើងត្រូវដោះស្រាយនៅពេលនេះគឺមិនមែនជារបៀបដែលបង្កើតតែក្រដាសប័ណ្ណកម្មសិទ្ធិទេ ប៉ុន្តែជារបៀបដែលធ្វើអោយប័ណ្ណនេះមានប្រសិទ្ធភាព យូរអង្វែង សមស្របចំពោះការការពារសិទ្ធិជនជាតិដើមភាគតិចដែលអនុវត្តតាមច្បាប់។ ខ្ញុំសំណូមពរដល់យើងទាំងអស់គ្នា កំណត់នូវវិធានការជាច្រើន ដែលអាចធានាថា វិធានការការពារបណ្តោះអាសន្ន គឺអនុវត្តបានយ៉ាងត្រឹមត្រូវ និងដីដែលមានប័ណ្ណកម្មសិទ្ធិគឺបានការពារយ៉ាងពេញលេញ។ ទោះបីជាការប្រឹងប្រែងយ៉ាងច្រើនក៏ដោយ បញ្ហាជាមូលដ្ឋាន ដូចជាការបង្កើតព្រំប្រទល់ដីនៃទ្រព្យសម្បត្តិដែលមានជម្លោះ បន្តញាំញីដល់សហគមន៍ជនជាតិដើមភាគតិច។

អនុញ្ញាតអោយខ្ញុំស្នើនូវសំណួរមួយចំនួនសម្រាប់ការពិគ្រោះយោបល់ ដែលមានចម្លើយអាចជួយត្រួសត្រាយផ្លូវទៅរកដំណោះស្រាយបាន។

ទី១ ខ្ញុំទទួលស្គាល់ថា មានការរៀបចំគម្រោង និងការអនុវត្តកំពុងដំណើរការ។ ទោះជាយ៉ាងណាក៏ដោយ វាគ្មានទៀងទាត់ ហើយទំនាក់ទំនងរវាងពួកគេតម្រូវអោយមានតម្លាភាព និងសហគមន៍ខ្លួនឯងត្រូវដឹងអោយបានច្បាស់នូវយន្តការនេះ និងមានសំឡេងខ្លាំងជាងនេះដែលជះឥទ្ធិពលដល់សេចក្តីសម្រេចដែល

ប៉ះពាល់លើពួកគាត់។ សំណួរទីមួយរបស់ខ្ញុំគឺថាតើដំណើរពិគ្រោះយោបល់អ្វីដែលបង្កើត ហើយមានកាតព្វកិច្ច មុនពេលសម្បទានដីណាមួយបន្ថែមទៀតផ្តល់អោយ? តើជាការទទួលខុសត្រូវរបស់អ្នកណាដែលធានាថាការពិភាក្សានេះនឹងបង្កើតឡើង?

ទី២ រហូតដល់ដំណោះស្រាយដ៏យូរអង្វែងមានប្រសិទ្ធភាព តើធនធានដី និងធនធានធម្មជាតិនៃសហគមន៍ជនជាតិដើមភាគតិចត្រូវបានការពារយ៉ាងដូចម្តេចក្នុងពេលនេះ? តើវិធានការបណ្តោះអាសន្នអ្វីគួរតែបង្កើតឡើងខណៈពេលព្រំប្រទល់ដីត្រូវបង្កើត ប័ណ្ណកម្មសិទ្ធិត្រូវបានអនុវត្ត និងត្រូវបានប្រគល់ និង បញ្ហាដីសម្បទានត្រូវបានដោះស្រាយ?

ទី៣ ដើម្បីឈានទៅដល់ដំណោះស្រាយដ៏យូរអង្វែង ដែលយើងទាំងគ្នាស្វែងរក តើដំណើរការនៃការទទួលបានកម្មសិទ្ធិជាសមូហភាពអាចធ្វើអោយមានភាពប្រសើរឡើងយ៉ាងដូចម្តេចសម្រាប់ជនជាតិដើមភាគតិច? តើអាជ្ញាធរមូលដ្ឋាន និងថ្នាក់ជាតិត្រូវបានគេទប់ស្កាត់យ៉ាងដូចម្តេចពីការបង្កើតឧបសគ្គថ្មីគ្រប់ពេលដែលឧបសគ្គចាស់រលាយបាត់? ចំពោះករណីនេះ តើព័ត៌មានអំពីដំណើរការនៃការផ្តល់ប័ណ្ណកម្មសិទ្ធិអាចមានតម្លាភាពយ៉ាងដូចម្តេច?

ទី ៤ យើងដឹងថាសហគមន៍ជនជាតិដើមភាគតិចដែលបានផ្តួចផ្តើមដំណើរការមួយ គឺគាត់ពឹងផ្អែកយ៉ាងខ្លាំងពីអង្គការអន្តររដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល ក្នុងការអនុវត្តប័ណ្ណកម្មសិទ្ធិដីសហគមន៍។ ដីដែលសំខាន់ក្នុងការការពារផ្លូវជីវិតរបស់ពួកគេ មិនមែនជារូបភាពទាំងមូលទេ។ តើការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុប៉ុន្មាន ដែលត្រូវការសម្រាប់ការពារបេតិកភណ្ឌវប្បធម៌ និងសិទ្ធិសម្រាប់ក្រុមនេះ?

មានសំណួរដែលខ្ញុំជឿជាក់ និងសោកស្តាយស្ថិតក្នុងសតិអារម្មណ៍របស់អ្នករាល់គ្នាអស់ជាច្រើនឆ្នាំ។ ចំណុចដែលសំខាន់នៃសំណួរលំបាកនេះជារឿយៗតែងកើតឡើងនៅពេលដែលគំនិត ថាមពល និងការកំណត់នៃស្ថាប័នពាក់ព័ន្ធ ដូចជា រដ្ឋាភិបាល សង្គមស៊ីវិល ដៃគូអន្តរជាតិ និងយ៉ាងហោចណាស់ ជនជាតិដើមភាគតិចខ្លួនឯង ត្រូវបញ្ជូនដោយបំណងរួមតាមរយៈការជួបប្រជុំដូចពេលនេះ។ វាចាំបាច់ដើម្បីការពារសហគមន៍ជនជាតិដើមភាគតិចពីការទុកពួកគេចោលទៀត ខណៈដែលកម្ពុជាបន្តបោះជំហានទៅមុខយ៉ាងខ្លាំងលើផ្លូវអភិវឌ្ឍន៍។

ជាចុងបញ្ចប់ ខ្ញុំជូនពរឲ្យអ្នកទទួលបានការពិគ្រោះយោបល់ដ៏មានផ្លែផ្កា និងអគុណសម្រាប់ការយកចិត្តទុកដាក់របស់អ្នក។